**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៣០ សហវ.ភាប៊ណ

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៣

# សេចក្តីជូនដំណឹង

~~~~~~

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជំរាបជូនដំណឹងដល់ម្ចាស់យានយន្តគ្រប់ប្រភេទដែលកំពុងចរាចរប្រើប្រាស់ ឬសន្និធិយានយន្តនៅតាមបណ្តាអាជីវកម្មដ្ឋាន លំនៅដ្ឋាន ឬកន្លែងផ្សេងទៀតក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ហើយកន្លងមកខកខានដោយប្រការណាមួយក្នុងការបំពេញបែបបទបង់ពន្ធ និងអាករនាំចូលស្របតាមច្បាប់ជាធរមាននោះឱ្យបានជ្រាបថា រាជរដ្ឋាភិបាលបានសំរេចកែសំរួលបន្ធូរបន្ថយកាតព្វកិច្ចពន្ធ និងអាករលើយានយន្តប្រភេទជាប់ពន្ធខ្ពស់មួយចំនួន ដែលនឹងដាក់ឱ្យអនុវត្តចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៤ នេះតទៅ ។

អាស្រ័យហេតុនេះ សូមម្ចាស់យានយន្តគ្រប់ប្រភេទដូចរៀបរាប់ខាងលើ ប្រញាប់ចូលខ្លួនមកបំពេញកាតព្វកិច្ចពន្ធ អាករនៅតាមបណ្តា សាខាគយនិងរដ្ឋាករខេត្ត ក្រុង និងការិយាល័យស្រាវជ្រាវ និងបង្ក្រាបអំពើរត់ពន្ធ នៃទីចាត់ការគយនិងរដ្ឋាករ ចាប់ពីថ្ងៃទី ០១ ដល់ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០០៤នេះ ។

ក្រោយកាលបរិច្ឆេទកំណត់ខាងលើនេះ ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចចុះបង្ក្រាប ឬចាប់ឃាត់ជាបណ្តោះអាសន្ននោះ យានយន្តល្មើសច្បាប់ទាំងនេះ នឹងត្រូវរងការបង្ខំឱ្យបង់ពន្ធ អាករ និងពិន័យតាមច្បាប់ជាធរមាន ឬបញ្ជូនករណីទាំងនេះទៅតុលាការមានសមត្ថកិច្ច ដើម្បីដោះស្រាយតាមផ្លូវច្បាប់ ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់ថា ម្ចាស់យានយន្តដូចរៀបរាប់ខាងលើ នឹងចូលខ្លួនដោយស្ម័គ្រចិត្តមកអនុវត្តតាមខ្លឹមសារសេចក្តីជូនដំណឹងនេះ ប្រកបដោយក្តីយោគយល់គ្នាទៅវិញទៅមក ដោយចាត់ទុកទង្វើនេះជាការចូលរួមដោយផ្ទាល់ក្នុងការកសាងសង្គមនីតិរដ្ឋនៅកម្ពុជា និងជៀសវាងនូវការប៉ះពាល់ជាអវិជ្ជមាននានា ក្នុងប្រតិបត្តិការបង្ក្រាបតាមបណ្តាអាជីវកម្មដ្ឋាន លំនៅដ្ឋាន ឬក្នុងពេលចរាចរប្រើប្រាស់នាពេលអនាគតដ៏ខ្លីខាងមុខជាក់ជាមិនខាន ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់
~~~~~~